# ទំនុកដំកើង ១៣២-១៣៤ ក្រុមទីប្រាំដែលមានទំនុកដំកើងបី។ (សូមមើលសេចក្តីនែនាំសំរាប់ទំនុកដំកើង ១២០-១៣៤) នៅពេលទៅដល់គោលដៅ

អ្នកនិពន្ធ រ៉ូហ្វ លេភិឡារ

ទំនុកដំកើងទាំងនេះសុទ្ធតែយកស៊ីយ៉ូនជាចំនុចកណ្តាល។ ការធ្វើដំណើរទៅថ្វាយបង្គំព្រះត្រូវបានបញ្ចប់ពីព្រោះពួកអ្នកធ្វើដំណើរទៅថ្វាយបង្គំព្រះបានមកដល់ស៊ីយ៉ូន។ ទោះយ៉ាងណា មានចលនានៅក្នុងទំនុកដំកើងទាំងបីនេះ: ចាប់ពីសេចក្តីពិតដែលថាព្រះយេហូវ៉ាបានជ្រើសរើសស៊ីយ៉ូននិងស្តេច (១៣២) ទៅដល់សេចក្តីប្រកបរបស់គ្រួសារនៃព្រះ (១៣៣) ហើយទៅដល់ការឈរនៅចំពោះព្រះអង្គទ្រង់ផ្ទាល់ (១៣៤)។ នេះជាទីបញ្ចប់នៃការធ្វើដំណើរទៅថ្វាយបង្គំព្រះ ព្រះអម្ចាស់គង់នៅជាមួយនឹងយើង (១៣២) ពួកជំនុំនៅក្នុងសេចក្តីប្រកបឥតខ្ចោះ (១៣៣) ពួកអ្នកបំរើរបស់ព្រះអម្ចាស់នៅក្នុងទីបរិសុទ្ធរបស់ព្រះអម្ចាស់ (១៣៤)។

## ទំនុកដំកើង ១៣២

នៅពេលហិបបានធ្វើដំណើរចំងាយខ្លីពីគារយ៉ាត់-យារីមទៅកាន់យេរូសាឡឹម វាគឺជាចំនុចខ្ពស់នៃការធ្វើដំណើរមួយជាច្រើនសតវត្សដែលបានចាប់ផ្តើមចំងាយមួយឆ្ងាយនៅឯស៊ីណាយ។ យ៉ាងហោចណាស់ទំនុកដំកើងពីរផ្សេងទៀតសរសេរអំពីព្រឹត្តិការណ៍នេះ គឺទំនុកដំកើង ២៤ និង៦៨។ ទំនុកដំកើង ១៣២ សង្កត់ធ្ងន់លើសារៈសំខាន់របស់ដាវីឌនៅក្នុងរឿងនេះ។ ទំនុកដំកើងនេះគឺជាការសញ្ជឹងគិតលើ២សាំយ៉ូអែល ៧ ដែលជាជំពូកដ៏សំខាន់ខ្លាំងមួយនៅក្នុងព្រះគម្ពីរ (ប្រសិនបើអ្នកមិនទាន់បានអានឬមិនចាំពី២សាំយ៉ូអែល ៧ សូមអានវាជាមួយនឹងទំនុកដំកើងនេះ)។ នៅក្នុង២សាំយ៉ូអែល ៧ ដាវីឌបានស្នើរឲ្យសាងសង់តំណាក់មួយសំរាប់ព្រះយ៉ាវេ ប៉ុន្តែព្រះយ៉ាវេបានឆ្លើយតបដោយការប្រកាសទៅកាន់ដាវីឌថា ទ្រង់នឹងសាងសង់តំណាក់ឲ្យដាវីឌវិញ ដូច្នេះទំនុកដំកើងនេះយើងអានអំពីសម្បថរបស់ដាវីឌ (ខ. ២-៥) និងសម្បថរបស់ព្រះអម្ចាស់ (ខ. ១០-១១)។ ទំនុកដំកើងនេះបែងចែកជាពីរផ្នែក ១-៩ និង ១០-១៨ ហើយផ្នែកនិមួយៗមានគំរូដូចគ្នា: សេចក្តីអធិស្ឋាន (១, ១០) សេចក្តីថ្លែង (២, ១១) ពាក្យសំដី (របស់ដាវីឌ ៣-៥ របស់ព្រះអម្ចាស់ ១១-១២) សេចក្តីថ្លែងបន្ថែមមួយ (៦, ១៣) ហើយនិងពាក្យសំដីចុងក្រោយមួយ (ការដាស់តឿន ៧-៩ និងសេចក្តីសន្យា ១៤-១៨)។ ដូច្នេះ សំណើរនិងសេចក្តីប្រាថ្នានានារបស់ដាវីឌស៊ីគ្នាជាមួយគោលបំណងនិងការអះអាងនានារបស់ព្រះ (១០-១៨)។ សម្បថរបស់ដាវីឌ (១-៥) តាមក្រោយដោយការប្តេជ្ញារបស់គាត់ក្នុងការបំពេញសំរេចសម្បថនោះ (៦-៩) ហើយនិងសម្បថរបស់ព្រះអម្ចាស់ (១០-១២) តាមក្រោយដោយការប្តេជ្ញារបស់ព្រះក្នុងការបំពេញសំរេចសម្បថរបស់ទ្រង់ (១៣-១៨)។

**ខ. ១** *សេចក្តីទុក្ខព្រួយ* វាជាការពិបាកក្នុងការនាំហិបមកកាន់ស៊ីយ៉ូនហើយមានទុក្ខលំបាកនៅតាមផ្លូវ (២សាំយ៉ូអែល ៦:៥-៩) កដូចជាការរៀបចំ តំលៃនិងការបាត់បង់ (២សាំយ៉ូអែល ៦:១២-២៣)។ ខនេះក៏អាចសំដៅទៅលើដាវីឌដែលកំពុងត្រូវបានបដិសេធជាអ្នកសាងសង់ព្រះវិហារផងដែរ (២សាំយ៉ូអែល ៧:៥, ១៣, ១ពង្សាវតាក្សត្រ ៥:៣, ១របាក្សត្រ ២២:៨, ២៨:៣)។

**ខ. ២** សម្បថនេះមិនត្រូវបានកត់ត្រាទុកក្នុងប្រវត្តិសាស្រ្តនោះទេ។ ដូច្នេះ ទំនុកដំកើងនេះកំពុងបន្ថែមពត៌មានឬនិយាយជាកំណាព្យអំពីភាពឆេះឆួលរបស់ដាវីឌដើម្បីជាសិរីល្អរបស់ព្រះក្នុងការធ្វើឲ្យស៊ីយ៉ូនក្លាយទៅជាទីក្រុងរបស់គាត់ហើយក្នុង

ការគ្រោងសំរាប់តំណាក់របស់ព្រះ។ *ព្រះដ៏ខ្លាំងពូកែ* (លោកុប្បត្តិ ៤៩:២៤, អេសាយ ៤៩:២៦, ៦០:១៦ ប្រៀបធៀបៈ អេសាយ ១:២៤) សង្កត់ធ្ងន់លើអំណាចរបស់ព្រះ។

**ខ. ៣-៥** ដាវីឌបង្ហាញភាពឆេះឆួលរបស់គាត់ដោយគាត់យកព្រះជាអាទិភាពខ្ពស់ជាងសេចក្តីត្រូវការនិងការចង់បានរបស់គាត់។ *ទីលំនៅ* « ទីលំនៅដែលល្អ/អស្ចារ្យ» ក៏មាននៅក្នុងខ. ៧ ផងដែរ។

**ខ. ៦** អត្ថន័យនៃពាក្យអេប្រាតាមិនច្បាស់លាស់នោះទេ ប៉ុន្តែវាមានទំនាក់ទំនងជាមួយបេថ្លេហិម (លោកុប្បត្តិ ៣៥:១៦ នាងរស់ ៤:១១ មីកា ៥:២)។ *វាលយ៉ាអើរ*ជាសរសេរកាត់សំរាប់ពួកគារយ៉ាត់-យារីម (១សាំយ៉ូអែល ៧:១-២) ជាកន្លែងដែលដាក់ហិបអស់រយៈពេលម្ភៃឆ្នាំ។

**ខ. ៧** *ពន្លា.....កំណល់កល់ព្រះបាទ។* សារៈសំខាន់របស់រោងឧបោសថ/ព្រះវិហារគឺថា វាគឺជាទីគង់នៅរបស់ព្រះក្នុងចំណោមប្រជារាស្ត្ររបស់ទ្រង់ (និក្ខមនំ ២៩:៤៣..., ១ពង្សាវតាក្សត្រ ៨:១០-១១, ១៣, ២៧)។ នៅក្នុងត្រសាល/ កន្លែងដំកល់ហិប ឬពាក្យផ្សេងទៀតហៅថា «ទីសន្តោសប្រោស» (និក្ខមនំ ២៥:១០-២២, លេវីវិន័យ ១៦:១៣-១៤) គឺជាកន្លែងដែលព្រះដ៏បរិសុទ្ធបានប៉ះផែនដី។ ហិបសម្ព័ន្ធមេត្រីត្រូវបានគេចាត់ទុកជាកំណល់កល់របស់បល្ល័ង្ករបស់ព្រះដែលមើលមិនឃើញ។ កំណល់កល់គឺជាផ្នែកសំខាន់របស់បល្ល័ង្កដែលតំណាងឲ្យការចូលទៅស្តេចជិតបំផុត។ រូបភាពអំពីកំណល់កល់មានសារៈសំខាន់ពីព្រោះវាត្រូវបានគេប្រើដើម្បីបញ្ជាក់អំពីពួកខ្មាំងសត្រូវនៅក្រោមបង្គាប់បញ្ជារបស់ព្រះ (សូមមើលទំនុកដំកើង ១១០:១)។ ការថ្វាយបង្គំនៅឯកំណល់កល់គឺជារបៀបមួយផ្សេងទៀតដើម្បីបញ្ជាក់អំពី ការកោតខ្លាចដែលត្រូវបានបង្ហាញតាមរយៈការក្រាបលំទោនខ្លួននៅឯព្រះបាទរបស់ព្រះ ឬស្តេច។ នេះគឺជាសកម្មភាពធម្មតានៃការចុះចូលចំពោះពួកស្តេចហើយនិងពួកព្រះ។ ការកាន់ព្រះបាទបានបង្ហាញអំពីការបន្ទាបខ្លួន ការចុះចូលនិងការអង្វរសុំ។ ទង្វើរនេះកើតមានឡើងយ៉ាងទូលំទូលាយនៅក្នុងអក្សរសាស្ត្ររបស់ពួកអាកាឌនៅពេលដែលអ្នករត់គេចឬអ្នកអង្វរកាន់ព្រះបាទរបស់ស្តេចដើម្បីបង្ហាញអំពីការចុះចូលឬការចុះចាញ់របស់ពួកគេ ហើយនិងការធ្វើបណ្តឹង របស់ពួកគេ។

**ខ. ៨** *សូមក្រោកឡើង* (ជនគណនា ១០:៣៥) *ព្រះចេស្តានៃទ្រង់* (យ៉ូស្វេ ៣:១១, ១សាំយ៉ូអែល ៥)។ *ទីសំរាក*មិនគ្រាន់តែជាកន្លែងមួយដែលព្រះសំរាកនោះទេ តែក៏ជាកន្លែងដែលប្រជារាស្ត្ររបស់ទ្រង់អាចចូលសេចក្តីសំរាករបស់ទ្រង់ផងដែរ។

**ខ. ៩** *ប្រដាប់ខ្លួន*។ ការប្រដាប់ខ្លួន ប្រៀបធៀបៈ ខ.១៦ ជានិមិត្តរូបនៃអត្តចរឹត តួនាទី និងការប្តេជ្ញាចិត្ត...ល. ធ្វើឲ្យពួកគេសុចរឹត។

**ខ. ១០** វគ្គទីពីរនៃទំនុកដំកើងនេះសំដៅទៅកាន់ឈ្មោះ*ដាវីឌ* ចំនួនបីដង (ខ. ១០, ១១, ១៧)។ គាត់នៅតែជាតួអង្គសំខាន់មួយបើទោះជាវគ្គនេះសង្កត់ធ្ងន់លើសកម្មភាពរបស់ព្រះក៏ដោយ។ *អ្នកដែលទ្រង់បានចាក់ប្រេងតាំង* គឺជាការបញ្ជាក់ដែលជារឿយត្រូវបានគេប្រើសំដៅទៅកាន់ស្តេច។ ប្រហែលជាខនេះបង្ហាញថា ទំនុកដំកើងនេះត្រូវបានសរសេរឡើងបន្ទាប់ពីសម័យរបស់ដាវីឌ គឺក្នុងកំឡុងរាជ្យរបស់ស្តេចផ្សេងទៀតដែលព្រះអង្គបានចាក់ប្រេងតាំង។

**ខ. ១១-១២** សម្បថដែលត្រូវបានលើកឡើងក្នុងខនេះគឺជាសម្បថដែលត្រូវបានកត់ត្រាទុកក្នុង២សាំយ៉ូអែល ៧ ហើយជាមូលដ្ឋានគ្រឹះសំរាប់គ្រប់យ៉ាងដែលព្រះអម្ចាស់បានធ្វើសំរាប់ស៊ីយ៉ូននិងពូជពង្សរបស់ដាវីឌ។ ព្រះយេស៊ូវបំពេញសំរេចសេចក្តីសន្យារបស់ព្រះយ៉ាងច្បាស់លាស់ (លូកា ១:៣២-៣៣)។ នេះជាមូលហេតុដែលអ្នកនិពន្ធព្រះគម្ពីរសញ្ញាថ្មីសង្កត់ធ្ងន់ថាព្រះយេស៊ូវគឺជាតំណរពូជរបស់ដាវីឌ។

**ខ. ១៣-១៦** នៅក្នុងចោទិយកថា ១២ ព្រះបានប្រាប់ជាមុនថាទ្រង់នឹងជ្រើសយកកន្លែងមួយសំរាប់ព្រះនាមរបស់ទ្រង់ ហើយបន្ទាប់មកព្រះបានបើកសំដែងថាទ្រង់បានជ្រើសយកយេរូសាឡឹម/ស៊ីយ៉ូន។ ទីក្រុងនេះគឺជាទីគង់នៅរបស់ព្រះអម្ចាស់ (ខ. ១៤ ប្រៀបធៀបៈ អេសេគាល ៤៨:៣៥, វិវរណៈ ២១:២-៣) ជាកន្លែងដែលទ្រង់ប្រទានពរខាងសម្ភារៈ (ខ. ១៥) និងខាងព្រលឹងវិញ្ញាណ (ខ. ១៦)។ ខ. ១៦ បង្ហាញយ៉ាងច្បាស់លាស់ថា នេះគឺជាការឆ្លើយតបរបស់ព្រះទៅចំពោះសំណូមពររបស់បណ្ដាជននៅក្នុងខ. ៩។

**ខ. ១៧-១៨** ខទាំងនេះគឺជាការឆ្លើយតបទៅនឹងសំណូមពរនៅក្នុងខ.១០។ ពាក្យទាំងបី *ស្នែង ចង្កៀង* និង *មកុដ* មានន័យថាកំលាំង ភាពភ្លឺថ្លា/ជីវិត និងសេចក្ដីថ្លៃថ្នូររបស់ស្ដេច។ ជាទូទៅ ស្នែងតំណាងឲ្យអំណាចឬឋានៈ។ នៅក្នុងចោទិយកថា ៣៣:១៧ ម៉ូសេបានសរសេរអំពីអំបូររបស់យ៉ូសែបថា «ឯកូនគោ របស់គេដែលកើតជាដំបូង នោះមានភាពស្វាហាប់ណាស់ ស្នែងវាដូចជាស្នែងនៃ ទន្សោង» ពីព្រោះបូជអំបូរអេប្រាអិមនិងម៉ាន៉ាសេធំនិងមានអំណាច។ ដូច្នេះ «ការលើកស្នែង» របស់នរណាម្នាក់ឡើងមានន័យថា ការប្រគល់អំណាច អំណរ សុខភាព និងកិត្តិនាម (ទំនុកដំកើង ៩២:១០, ១សាំយ៉ូអែល ២:១)។ «ការកាត់ស្នែងចោល» គឺជាការដកហូតអំណាចឬឥទ្ធិពលរបស់នរណាម្នាក់ចេញ (ទំនុកដំកើង ៧៥:១០, យេរេមា ៤៨:២៥)។ ដោយសារតែព្រះគឺជាប្រភពនៃកំលាំងសំរាប់អស់អ្នកណាដែលទុកចិត្តដល់ទ្រង់ ដាវីឌប្រកាសថា «ព្រះអម្ចាស់គឺជា...ស្នែងនៃសេចក្ដីសង្គ្រោះរបស់ទូលបង្គំ ហើយជាប៉មយ៉ាងខ្ពស់ផង» (ទំនុកដំកើង ១៨:២, ២សាំយ៉ូអែល ២២:៣)។ ដោយព្រោះស្នែងគឺជានិមិត្តសញ្ញានៃអំណាចរបស់ស្ដេច នោះស្នែងត្រូវបានគេប្រើជានិមិត្តសញ្ញាដើម្បីតំណាងឲ្យអ្នកដែលព្រះជាម្ចាស់បានចាក់ប្រេងតាំងឲ្យ (ព្រះមែស៊ី)។

ជារឿយៗអ៊ីស្រាអែលបានយកចង្កៀងដើម្បីបញ្ជាក់ន័យឲ្យជីវិតនិងភាពចំរុងចំរើន។ ជារឿយៗព្រះគម្ពីរបានប្រើ«ចង្កៀងរបស់ទ្រង់»ដើម្បីបញ្ជាក់ន័យឲ្យជីវិត។ អណ្ដាតភ្លើងដែលមិនរលត់គឺជានិមិត្តសញ្ញាមួយនៃការអត់ធន់និងការចងចាំ។ ភាសារបស់ពួកយូហ្គារីតនិងពួកអាកាឌក៏បានប្រើរូបភាពចង្កៀងជានិមិត្តសញ្ញានៃការគ្រប់គ្រងជានិច្ចឬព្រះវត្តមានរបស់ព្រះ។ ស៊ីយ៉ូនគឺជាកន្លែងសំរាប់ការយាងមករបស់ព្រះមែស៊ីនិងជ័យជំនះរបស់ទ្រង់។ ដូច្នេះ ខ.១៧-១៨ គឺជាទំនាយយ៉ាងច្បាស់អំពីការយាងមករបស់ព្រះមែស៊ី។ អនាគតរបស់ព្រះមែស៊ីគឺផ្ទុយគ្នាទាំងស្រុងពីអនាគតរបស់ពួកខ្មាំងសត្រូវរបស់ទ្រង់។ ទ្រង់នឹងបានរុងរឿង ឯពួកខ្មាំងសត្រូវរបស់ទ្រង់នឹងបានប្រដាប់ដោយសេចក្ដីខ្មាស់។ ដូច្នេះ ទំនុកដំកើងដែលចាប់ផ្ដើមដោយទុក្ខលំបាក បញ្ចប់ដោយសិរីល្អរបស់ស្ដេចដែលព្រះសន្យាថានឹងមានជ័យជំនះនិងរស្មីចែងចាំង។

**ការអនុវត្ត**

ការសន្យាផ្សេងៗមានសារៈសំខាន់ណាស់នៅក្នុងភាពឧទ្ទិសចំពោះព្រះតាមព្រះគម្ពីរ។ ផ្ទៃរឿងអំពីព្រះធ្វើការសន្យា ហើយបន្ទាប់មកបំពេញសំរេចសេចក្ដីសន្យាទាំងនោះគឺជាកត្តាចំបងមួយក្នុងការបង្កើតរចនាសម្ព័ន្ធរបស់ព្រះគម្ពីរ។ នៅទីនេះយើងឃើញថាប្រជារាស្ត្ររបស់ព្រះគួរតែច្រៀងអំពីសេចក្ដីសន្យារបស់ព្រះ។ វាមិនមែនជាអ្វីដែលយើងគ្រាន់តែសិក្សាដើម្បីយល់ព្រះគម្ពីរហើយបន្ទាប់មកភ្លេចនៅពេលដែលយើងទាក់ទងនឹងព្រះនោះទេ។ ការទុកចិត្តលើសេចក្ដីសន្យារបស់ព្រះនិងការសរសើរសេចក្ដី ស្មោះត្រង់របស់ព្រះចំពោះសេចក្ដីសន្យារបស់ទ្រង់គឺជាចំនុចកណ្ដាលនៃទំនាក់ទំនងរបស់យើងជាមួយព្រះ។ ទំនុកដំកើងនេះ បង្ហាញគោលការណ៍នេះនៅពេលពួកអ៊ីស្រាអែលបានច្រៀងអំពីសេចក្ដីសន្យាពេលមុនរបស់ព្រះទៅកាន់ដាវីឌថា ព្រះរាជបុត្រារបស់ដាវីឌនឹងគ្រប់គ្រងជារៀងរហូត (២សាំយ៉ូអែល ៧)។ ពួកគ្រីស្ទបរិស័ទកាន់តែ

មានហេតុផលក្នុងការច្រៀងព្រោះយើងរស់នៅបន្ទាប់ពីការយាងមករបស់ព្រះយេស៊ូវដែលជាព្រះបុត្រារបស់ដាវីឌដែលបានបំពេញសំរេចសេចក្តីសន្យាទាំងនោះ។ សេចក្តីសន្យាទាំងនេះមកពីសេចក្តីស្រលាញ់របស់ព្រះ ហើយទាមទារឲ្យយើងស្រលាញ់ព្រះវិញ។ ទោះយ៉ាងណា ពេលខ្លះយើងមិនឆ្លើយតបនៅក្នុងផ្លូវត្រឹមត្រូវនោះទេ។ ជាឧទាហរណ៍ ពួកអ៊ីស្រាអែលបានប្រើការប្តេជ្ញារបស់ព្រះចំពោះយេរូសាឡឹមជាជំរកប្រឆាំងនឹងការវិនិច្ឆ័យរបស់ទ្រង់ហើយដូច្នេះជាការដោះសារក្នុងការបះបោរ (យេរេមា ៧ ជាពិសេសខ. ៨-១៥)។ អស់អ្នកដែលមិនទាន់ជឿលើព្រះយេស៊ូវគួរតែធ្វើដូច្នោះ ឬពួកគេនឹងបានប្រដាប់ដោយសេក្តីខ្មាស (ខ. ១៨)។ សំរាប់ពួកគ្រីស្ទបរិស័ទវិញ យើងមានអំណរនិងសេចក្តីសង្គ្រោះហើយយើងថ្វាយបង្គំស្តេចមួយអង្គដែល *ព្រះកេសទ្រង់នឹងមានមកុដដ៏រុងរឿង*។

**Bibliography**


Carson, D.A., R. T. France, J. A. Motyer & G. J. Wenham, Ed. (1994), *New Bible commentary: 21st century edition*, (4th ed.)  Leicester, England; Downers Grove, IL: Inter-Varsity Press.

Keil, C. F., & Delitzsch, F. (1996). *Vol. 5*: *Commentary on the Old Testament*. Peabody, MA: Hendrickson.

Kidner, D. (1975). *Vol. 16*: *Psalms 73–150: An Introduction and Commentary*. Tyndale Old Testament Commentaries (465–467). Nottingham, England: Inter-Varsity Press.

Matthews, V. H., M. W. Chavalas & J.H. Walton (2000), *The IVP Bible background commentary: Old Testament*, Downers Grove, IL: InterVarsity Press.

Wilcock, M. (2001), *The Message of Psalms 73-150.*  The Bible Speaks Today Commentaries. Leicester, England: Inter-Varsity Press.